# ចូឡសុខជាតក

(បិដកខ្មែរថា ចុល្លសុវកោរាជជាតក)



ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធវេរញ្ជកណ្ឌ (វិនយបិដកលេខ ១ ទំព័រ ១) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **សន្តិ រុក្ខា** ដូច្នេះជាដើម ។

កាលព្រះសាស្តាគង់នៅចាំវស្សាក្នុងស្រុកវេរញ្ជា ហើយយាងតាមលំដាប់មកដល់ក្រុងសាវត្ថី ភិក្ខុទាំងឡាយញ៉ាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ព្រះតថាគតជាខត្តិយសុខុមាលជាតិ ជាពុទ្ធសុខុមាលជាតិ ទ្រង់ប្រកបដោយឥទ្ធានុភាពច្រើន កាលនៅចាំវស្សាអស់ ៣ ខែដោយការនិមន្តរបស់វេរញ្ជព្រាហ្មណ៍ ទ្រង់មិនបានភិក្ខាសូម្បីតែមួយថ្ងៃអំពីសម្នាក់ព្រាហ្មណ៍នោះ ដោយអំណាចនៃមារបង្ខិលចិត្ត ទ្រង់លះសេចក្តីល្មោភក្នុងអាហារ ទ្រង់ញ៉ាំងព្រះជន្មឲ្យប្រព្រឹត្តទៅដោយអាហារសម្រាប់សេះមួយនាឡិអស់ ៣ ខែ ស្តេចមិនយាងទៅក្នុងទីដទៃ សេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោសរបស់ព្រះតថាគតអស្ចារ្យណាស់ ។ ព្រះសាស្តាយាងមកហើយសួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ

អង្គុយប្រជុំគ្នាដោយរឿងអ្វី ។ កាលភិក្ខុទាំងឡាយទូលថា ដោយរឿងឈ្មោះនេះ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការលះសេចក្តីល្មោភក្នុងអាហារ ក្នុងកាលឥឡូវនេះ របស់តថាគត មិនជាអស្ចារ្យទេ សូម្បីក្នុងកាលមុន កាលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ក៏លះសេចក្តីល្មោភក្នុងអាហារដែរ ដូច្នេះហើយ ព្រះអង្គទើបនាំអតីតនិទានមក ។

រឿងរ៉ាវសូម្បីទាំងអស់ អ្នកសិក្សាគប្បីឲ្យពិស្តារដោយន័យដំបូងនោះឯង ។

(ស្តេចហង្សនិយាយនឹងស្តេចសេកថា)

សន្តិ រុក្ខា ហារិបត្តា, ទុមា នេកផលា ពហូ;
កស្មា នុ សុក្ខេ កោឡាបេ, សុវស្ស និរតោ មនោ។

ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះ មានចិត្តរីករាយជានិច្ច តែនឹងដង្គត់ឈើពុកស្ងួត ។

(ស្តេចសេកនិយាយតបវិញថា)

ផលស្ស ឧបភុញ្ជិម្ហា, នេកវស្សគណេ ពហូ;
អផលម្បិ វិទិត្វាន, សាវ មេត្តិ យថា បុរេ។

យើងបានចូលទៅបរិភោគផ្លែឈើនោះ រាប់ដោយឆ្នាំច្រើនជាអនេក ទោះបីយើងដឹងថា ឈើនោះ មិនមានផ្លែហើយ ការមេត្រីនោះ ក៏នៅដូចដើម ។

(ស្តេចហង្សនិយាយថា)

សុក្ខញ្ច រុក្ខំ កោឡាបំ, ឱបត្តមផលំ ទុមំ;
ឱហាយ សកុណា យន្តិ, កិំ ទោសំ បស្សសេ ទិជ។

*សត្វស្វាបទាំងឡាយ តែងលះបង់នូវដើមឈើដែលពុកស្ងួត ជ្រុះស្លឹកអស់ មិនមានផ្លែ ហើយហើរទៅ ម្នាលអ្នកជាទ្វិជាតិ អ្នកសម្គាល់ឃើញទោស (ក្នុងការលះចោលនោះ) ដូចម្ដេច ។*

*(ស្ដេចសេកនិយាយថា)*

យេ ផលត្ថា សម្ភជន្តិ, អផលោតិ ជហន្តិ ឆំ;
អត្តត្ថបញ្ញា ទុម្មេធា, តេ ហោន្តិ បក្ខចាតិនោ។

*ពួកសត្វណា មានសេចក្ដីត្រូវការដោយផ្លែ ហើយគប់រកនូវដើមឈើ លុះដឹងថា មិនមានផ្លែ ក៏លះចោលនូវដើមឈើនោះ ពួកសត្វស្វាបនោះ ឈ្មោះថាមានប្រាជ្ញាគិតតែប្រយោជន៍ផ្ទាល់ខ្លួន មានប្រាជ្ញាមិនល្អ រមែងញ៉ាំងចំណែកនៃសេចក្ដីរាប់អានឲ្យវិនាស ។*

*(ស្ដេចហង្សនិយាយថា)*

សាធុ សក្ខិ កតំ ហោតិ, មេត្តិ សំសតិ សន្ថវោ;
សចេតំ ធម្មំ រោចេសិ, ចាសំសោសិ វិជានតំ។

*ម្នាលបក្សី សេចក្ដីមេត្រី សេចក្ដីជួបជុំ និងសេចក្ដីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តធម៌នេះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។*

សោ តេ សុវ វរំ ទម្មិ, បត្តយាន វិហង្គម;
វរំ វរស្សុ វក្កង្គ, យំ កិញ្ចិ មនសិច្ឆសិ។

*ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅតាមអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណានីមួយ ចូរទទួលយកពរនោះចុះ ។*

*(ស្ដេចសេកនិយាយថា)*

អបិ ជាម ធំ បស្សេយ្យំ, សបត្តំ សផលំ ទុមំ;
ឧលិទ្ធោវ ធិជ៏ លទ្ធា, ឆន្ទេយ្យាហំ បុនប្បុនំ។

*ខ្ញុំសូមឲ្យបានឃើញនូវដើមឈើនោះ មានស្លឹក និងផ្លែឡើងវិញដូចដើម ខ្ញុំគប្បីរីករាយរឿយ ៗ ដូចមនុស្សកម្សត់ បានកំណប់ទ្រព្យ ។*

*(អភិសម្ពុទ្ធគាថា)*

តតោ អមតមាទាយ, អភិសិញ្ចិ មហីរុហំ;
តស្ស សាខា វិរូហឹសុ, សីតច្ឆាយា មនោរមា។

*លំដាប់នោះ ព្រះឥន្ទបានយកទឹកអម្រឹត មកស្រោច នូវឈើដុះលើផែនដី ដើមឈើនោះ មានមែកលូតលាស់ត្រសាយត្រសុំ មានម្លប់ដ៏ត្រជាក់ ជាទីរីករាយនៃចិត្ត ។*

*(ស្តេចសេកនិយាយថា)*

ឯវំ សក្ក សុខី ហោហិ, សហ សព្ពេហិ ញាតិភិ;
យថាហមជ្ជ សុខិតោ, ទិស្វាន សផលំ ទុមំ។

*បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចជាខ្ញុំដែលបានសេចក្តីសុខ ព្រោះឃើញនូវដើមឈើដ៏ប្រកបដោយផ្លែ ក្នុងថ្ងៃនេះ ។*

*(អភិសម្ពុទ្ធគាថា)*

សុវស្ស ច វរំ ទត្វា, កត្វាន សផលំ ទុមំ;
បក្កាមិ សហ ភរិយាយ, ទេវានំ នន្ទនំ វនំ។

*ព្រះឥន្ទបានឲ្យពាក្យសេកហើយ ក៏ធ្វើនូវឈើនោះ ឲ្យមានផ្លែ រួចក៏ចៀសចេញទៅកាន់ននួនវនឧទ្យាន នៃទេវតាទាំងឡាយ ជាមួយនឹងភរិយា ។*

*សូម្បីបញ្ហានិងពាក្យតបបញ្ហា សូម្បីអត្ថសេចក្តី អ្នកសិក្សាគប្បីជ្រាបតាមន័យដំបូង នោះឯង ចំណែកក្នុងជាតកនេះ ខ្ញុំនឹងពណ៌នាបទដែលលំបាកប៉ុណ្ណោះ ។*

*បទថា* **ហារិបត្តា** *សេចក្តីថា ដេរដាសដោយស្លឹកពណ៌ខៀវ ។ បទថា* **កោឡាបេ** *សេចក្តីថា ដែលមិនមានខ្លឹម កាលខ្យល់បក់ មានសំឡេងដូចគេសំពង ។ បទថា* **សុវស្ស** *សេចក្តីថា ព្រោះហេតុអ្វី ស្តេចសេកសុវរាជដ៏មានអាយុមានចិត្តត្រេកអរសេិប់នឹងដើមឈើ ដែលមានសភាពបែបនោះ ។ បទថា* **ផលស្ស** *សេចក្តីថា ផ្លៃដើមឈើនោះ។ បទថា* **ពេក-វស្សគណេ** *សេចក្តីថា ជាច្រើនឆ្នាំ ។ បទថា* **ពហូ** *សេចក្តីថា សូម្បីអស់កាលច្រើនរយឆ្នាំ មិនមែន ២ ឆ្នាំ មិនមែន ៣ ឆ្នាំ គឺច្រើន ។ បទថា* **វិទិត្វាន** *សេចក្តីថា សេកសុវរាជកាលប្រកាស សេចក្តីនោះទើបពោលថា បពិត្រស្តេចហង្ស ឥឡូវនេះ សូម្បីខ្ញុំដឹងថា ដើមឈើនេះមិនមាន ផ្លៃ មេត្រីភាពជាមួយនឹងដើមឈើនោះក្នុងកាលមុនយ៉ាងណា មេត្រីភាពនោះ ពួកខ្ញុំនឹងមិន ទម្លាយមេត្រីភាពនោះ ព្រោះថាអ្នកដែលទម្លាយមេត្រីភាព ឈ្មោះថា ជាមនុស្សមិនល្អ ជា អសប្បុរស ។*

*បទថា* **អមិ ជាម ធំ** *សេចក្តីថា បពិត្រស្តេចហង្ស បើសេចក្តីប្រាថ្នារបស់ខ្ញុំគប្បីបាន ពរ ដែលលោកឲ្យ គប្បីសម្រេច ខ្ញុំចង់ឃើញដើមឈើនេះមានស្លឹក មានផ្លៃម្តងទៀត បន្ទាប់មក ខ្ញុំដែលជាសត្វកម្សត់បានកំណាប់នេះ នឹងគប្បីត្រេកអរនឹងដើមឈើនោះរឿយៗ កាលបាន ឃើញដើមឈើនោះ ខ្ញុំនឹងមានចិត្តរីករាយ ។ បទថា* **អមតមាទាយ** *សេចក្តីថា បិតនៅ ដោយអានុភាពរបស់ខ្លួន កាន់យកទឹកទន្លេគង្គា មកស្រោច ។ ក្នុងជាតកនេះ មានអភិសម្ពុទ្ធ គាថា ២ មួយអន្ទើដោយគាថាទាំងឡាយនេះ ។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា សក្កោ អនុរុទ្ធោ អហោសិ** *ស្តេចសក្កៈក្នុងកាលនោះ បានមកជា អនុរុទ្ធ*

**សុវាជា បន អហមេវ អហោសិំ** *ស្តេចសេកសុវរាជ គឺ តថាគត នេះឯង ។*

*ចប់ ចូឡសុវជាតក ៕*

(*ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក នវកនិបាត បិដកលេខ ៥៩ ទំព័រ ១៤២*)

*ថ្ងៃច័ន្ទ ៩ កើត ខែវិសាខ ឆ្នាំច សំរិទ្ធិស័ក ច.ល. ១៣៨០*

*ថ្ងៃទី ២៣ ខែមេសា ព.ស. ២៥៦១ គ.ស.២០១៨*

*ដោយ ស.ដ.វ.ថ.*